ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រារព្ធពិធីអបអរសាទរខួបលើកទី២៣ ទិវាពិភពលោក ដើម្បីសុវត្ថិភាពនិងសុខភាពការងារ

"ទិវាពិភពលោក ដើម្បីសុវត្ថិភាពនិងសុខភាពការងារ" ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី២៨ ខែមេសា ដោយប្រទេសជាសមាជិកនៃអង្គការអន្តរជាតិខាងការងារ ដើម្បីលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារ និងរំលឹកដល់វិញ្ញាណក្ខន្ធបងប្អូនកម្មករនិយោជិត ដែលបានបាត់បង់ជីវិតដោយសារគ្រោះថ្នាក់ការងារនិងជំងឺវិជ្ជាជីវៈនៅលើពិភពលោក។ នៅឆ្នាំ២០២៦នេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំពិធីអបអរសាទរខួបលើកទី២៣ ទិវាពិភពលោក ដើម្បីសុវត្ថិភាពនិងសុខភាពការងារ ក្រោមប្រធានបទ "រួមគ្នាបន្តការពារកម្មករនិយោជិតពីភាពតានតឹងដោយកម្តៅ និងលើកកម្ពស់សុខភាពផ្លូវចិត្តនៅកន្លែងធ្វើការ" នៅថ្ងៃពុធ ១២រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៦ នៅតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ ដោយមានសមាសភាពចូលរួមមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិខាងការងារ តំណាងសមាគមនិយោជក តំណាងសហជីព អង្គការនិងដៃគូអភិវឌ្ឍន៍ និងបងប្អូនកម្មករនិយោជិត សរុបប្រមាណ ១ ៣០០នាក់។

ដើម្បីអបអរសាទរទិវាពិភពលោកនេះ និងរួមចំណែកក្នុងការផ្សព្វផ្សាយការលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារ ព្រមទាំងការបង្ការគ្រោះថ្នាក់ការងារនិងជំងឺវិជ្ជាជីវៈដោយថាហេតុ ដល់បងប្អូនកម្មករនិយោជិត ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រទាំងអស់ ត្រូវរៀបចំចងបដាពាក្យស្លោកមួយចំនួននៅតាមរបងខាងមុខសហគ្រាស ក្រុមហ៊ុន រោងចក្រ នូវខ្លឹមសារដូចខាងក្រោម៖

១- អបអរសាទរទិវាពិភពលោក ដើម្បីសុវត្ថិភាពនិងសុខភាពការងារ ២៨ មេសា។
២- រួមគ្នាបន្តការពារកម្មករនិយោជិតពីភាពតានតឹងដោយកម្តៅ និងលើកកម្ពស់សុខភាពផ្លូវចិត្តនៅកន្លែងធ្វើការ។
៣- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើផ្នែកសុវត្ថិភាពនិងសុខភាពការងារ។
៤- ធ្វើសកម្មភាពរួមគ្នាដើម្បីកសាងវប្បធម៌សុវត្ថិភាពនិងសុខភាពការងារជាវិជ្ជមាន។
៥- ត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនិងសុខភាពការងារនៅគ្រប់កន្លែងធ្វើការ។
៦- មានសុវត្ថិភាពការងារ គឺគ្មានគ្រោះថ្នាក់ការងារ។
៧- ធានាឱ្យគ្រប់កន្លែងការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានសុវត្ថិភាពល្អ។
៨- រួមគ្នាកាត់បន្ថយគ្រោះថ្នាក់ការងារនិងជំងឺវិជ្ជាជីវៈ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៩- ជីវិតរបស់ខ្ញុំ ការងាររបស់ខ្ញុំ និងការងារប្រកបដោយសុវត្ថិភាពរបស់ខ្ញុំ។

១០- ការងារសមរម្យ គឺជាការងារប្រកបដោយសុវត្ថិភាព។

១១- បរិយាកាសការងារប្រកបដោយសុវត្ថិភាពនិងសុខភាពការងារ គឺជាសិទ្ធិនិងគោលការណ៍គ្រឹះនៅកន្លែងធ្វើការ។

១២- រួមគ្នាលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ តាមរយៈការប្រើប្រាស់ប្រព័ន្ធឌីជីថលនិងបញ្ញាសិប្បនិម្មិត (AI)។

១៣- ជំរុញការប្រើប្រាស់ឧបករណ៍និងប្រព័ន្ធតាមដានឆ្លាតវៃ ដើម្បីជួយសហគ្រាស ក្រុមហ៊ុន រោងចក្រ វាយតម្លៃហានិភ័យនិងចាត់វិធានការឆ្លើយតបលើសុវត្ថិភាពនិងសុខភាពការងារឱ្យបានទាន់ពេលវេលា។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ អង្គការវិជ្ជាជីវៈ និងបងប្អូនកម្មករនិយោជិតទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ៧រោច ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ២០២៦